# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ២៧៣,០៣៧ ដុល្លារអាមេរិកដើម្បីកាត់បន្ថយភាពក្រីក្រ នៅតំបន់ជនបទតាមរយៈការបង្កើតនូវការគ្រប់គ្រងដែលមាននិរន្តរភាព ក្នុងសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង (ដំណាក់កាលទី២)



ក្រោមគ្រោងការណ៍នៃជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ¥២២,៣៨៩,០៣៤ ស្មើនឹងប្រមាណ ២៧៣,០៣៧ដុល្លារអាមេរិកដល់ក្រុមអ្នកស្ម័គ្រចិត្តអន្តរជាតិរបស់យ៉ាម៉ាហ្គាតា (អាយ.វី.វ៉ាយ)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូត វិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី ម៉ាត់ស៊ូរ៉ា អាយូមី នាយិកា អង្គការ អាយ.វី.វ៉ាយ នៅស្ថានទូតជប៉ុន សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ តាមរយៈការបង្កើតនូវការគ្រប់គ្រងដែលមាននិរន្តរភាពក្នុងសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC)ដំណាក់កាលទី២។



តាមរយៈគម្រោងនេះ អង្គការ អាយ.វី.វ៉ាយ នឹងជួយគាំទ្រដើម្បីធ្វើឲ្យមានស្ថេរភាពក្នុងការគ្រប់គ្រងរបស់សហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC)។ ជាពិសេសអាយ.វី.វ៉ាយនឹងផ្តល់ការបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនដល់ SAC ដែលរួមមានជាអាទិ៍ ការគ្រប់គ្រងក្រុមហ៊ុន អាជីវកម្មក្នុងសហគមន៍ និងភាពជាអ្នកដឹកនាំជាដើម។ ជាងនេះទៅទៀត ច្រកសម្រាប់ដឹកជញ្ជូន និង ចែកចាយផលិតផលកសិកម្មរបស់ SAC ទៅកាន់ផ្សារទំនើបជប៉ុននៅភ្នំពេញក៏នឹងត្រូវបានបង្កើតឡើងក្នុងគម្រោងនេះផងដែរ។ ដូច្នេះយើងរំពឹងថា SAC នឹងជួយបង្កើនចំណូលដល់ប្រជាកសិករដែលនឹងនាំឲ្យមានការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ១៩.៨ លានដុល្លារអាមេរិកដល់គម្រោងចំនួន ៧៥ គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលផ្តោតសំខាន់ទៅលើ វិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និងសកម្មភាពបោសសំអាតមីន។ គម្រោងរបស់អង្គការ អាយ.វី.វ៉ាយ នេះគឺជាគម្រោងទី៥ តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៣របស់ជប៉ុន (មេសា២០១៣ ដល់ មិនា ២០១៤) ។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*

*អ៊ីមែល:* eco.jpn@pp.mofa.go.jp

*គេហទំព័រ:* http://www.kh.emb-japan.go.jp